**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**បេឡាជាតិសន្តិសុខសង្គម**

លេខ : ០១៧/២៦ ប.ស.ស.

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបញ្ចប់កិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាលរវាង ប.ស.ស. និងមូលដ្ឋានសុខាភិបាលឯកជន ចំនួន២ ក្នុងការផ្តល់សេវាជូនសមាជិក ប.ស.ស.

**បេឡាជាតិសន្តិសុខសង្គម** (ប.ស.ស.) **នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ សាធារណជន ម្ចាស់រោងចក្រ សហគ្រាស គ្រឹះស្ថាន និងសមាជិក **ប.ស.ស.** ទាំងអស់មេត្តាជ្រាបថា **បេឡាជាតិសន្តិសុខសង្គម** (ប.ស.ស.) បានបញ្ចប់កិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាលជាមួយមូលដ្ឋានសុខាភិបាលឯកជន ចំនួន២ ដែលមានឈ្មោះ និងអាសយដ្ឋានដូចខាងក្រោម៖

| | |
|---|---|
| -មន្ទីរសម្រាកព្យាបាល ទំនប់ធំ | ៖ផ្ទះគ្មានលេខ ផ្លូវជាតិលេខ៥១ ឃុំទំនប់ធំ ស្រុកពញាឮ ខេត្តកណ្តាល។ |
| -មន្ទីរសម្រាកព្យាបាល អេស វី សម្បត្តិវឌ្ឍនៈ | ៖ផ្ទះគ្មានលេខ ផ្លូវលេខ១០៦A សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។ |

ក្នុងន័យនេះ **ប.ស.ស.** នឹងមិនធ្វើការទូទាត់ថ្លៃសេវាព្យាបាល និងថៃទាំវេជ្ជសាស្ត្រជូនមូលដ្ឋានសុខាភិបាលឯកជនទាំងពីរខាងលើ តាមរយៈការចូលប្រើប្រាស់សេវារបស់សមាជិក **ប.ស.ស.** ចាប់ពីកាលបរិច្ឆេទនៃការចេញលិខិតជូនដំណឹងនេះតទៅ ករណីសមាជិក **ប.ស.ស.** ចូលប្រើប្រាស់សេវានៅមូលដ្ឋានសុខាភិបាលខាងលើនោះការចំណាយជាបន្ទុកផ្ទាល់របស់អ្នកជំងឺ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ម្ចាស់រោងចក្រ សហគ្រាស គ្រឹះស្ថាន និងសមាជិក **ប.ស.ស.** មេត្តាជ្រាបជាព័ត៌មាន និងផ្សព្វផ្សាយសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ចន្ទ ១៤កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ២០២៦

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**

**អគ្គនាយកបេឡាជាតិសន្តិសុខសង្គម**

**ម៉េង ហុង**